ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៣៨
ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩
សាលដីកា
លេខ: ៣៤ "VIII"
ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០

# សាលដីកា
# តាងនាមប្រជារាស្ត្រខ្មែរ
# តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០
ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម ៖

១.ឯកឧត្តម [redacted] ប្រធាន
២.លោក [redacted] ចៅក្រម
៣.លោក [redacted] ចៅក្រម
៤.លោក [redacted] ចៅក្រម
៥.លោក [redacted] ចៅក្រម(របាយការណ៍)

## ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted]

## តំណាងមហាអយ្យការ

ឯកឧត្តម [redacted] អគ្គព្រះរាជអាជ្ញារង

## ដើម្បីជំនុំជម្រះ

លើបណ្ដឹងសាទុក្ខលេខ ១៩៦ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩ របស់លោក [redacted] ម៉ាលីស៊ីន ជាមេធាវីការពារឱ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ីប៊ីរ ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៥៤ ក្រ.III "ស.អ" ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩ របស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ ដែលមាន ៖

-ជនត្រូវចោទឈ្មោះ [redacted] ស៊ីម៉េង ភេទប្រុស អាយុ៤៤ឆ្នាំ ជាតិខ្មែរ មុខរបរទិញ-លក់ដី ទីកន្លែងកំណើតនៅសង្កាត់លេខ៥ ខណ្ឌចាក់អង្រែលើ រាជធានីភ្នំពេញ មានទីលំនៅបច្ចុប្បន្ន [redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] "ស" ម្ដាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន ០៣នាក់ ទោសពីមុនគ្មាន ។



Scanned with CamScanner

ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទៈ ឆបោក និងរំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅភូមិប្រិយ៍ ឃុំខ្នារសណ្តាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប កាលពីអំឡុងឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧, ៣៧៨, ៣៩១ និងមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ីវចឺវ ភេទប្រុស អាយុ៦៦ឆ្នាំ ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន [redacted] រាជធានីភ្នំពេញ ។ (អ្នកប្តឹងសាទុក្ខ)

**អំពីអង្គហេតុៈ**

តាមពាក្យបណ្តឹង ឈ្មោះ [redacted] ស៊ីងប៊ីវ បានចោទប្រកាន់ថា កាលពីអំឡុងឆ្នាំ២០១៧ មានករណីឆបោក និងរំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅចំណុចភូមិប្រិយ៍ ឃុំខ្នារសណ្តាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ដែលបង្កឡើងដោយជនសង្ស័យឈ្មោះ [redacted] ស៊ីម៉េង និងបក្សពួកបានបបួលជនរងគ្រោះឈ្មោះ [redacted] ស៊ីងប៊ីវ មករកស៊ីទិញ-លក់ដីជាមួយគ្នា ដោយជនសង្ស័យបានប្រើឧបាយកល ថាត្រូវ ទិញ ដីចំនួន ១៤ ហិកតា ស្មើនឹង ១៤០.០០០ ម៉ែត្រការ៉េ ដែលមានទីតាំងនៅ ចំណុចកើតហេតុខាងលើ ទុកសម្រាប់សាងសង់ផ្ទះលក់បន្ត ដោយដាក់ទុន ៥០% ម្នាក់។ ចំពោះតម្លៃដីវិញ ចន្លោះពី ២$ ទៅ ៤$ ក្នុង១ម៉ែត្រការ៉េតែប៉ុណ្ណោះ ។ បន្ទាប់ពីស្តាប់ការលួងលោមហើយ ជនរងគ្រោះក៏យល់ព្រមប្រគល់លុយគ្រប់ចំនួនតាមការទាមទារ។ ក្រោយពីជនសង្ស័យបានទទួលប្រាក់ហើយ ស្រាប់តែជននេះទិញដីបាន ២កន្លែង ប្រហែលជាង ២ហិកតា ប៉ុណ្ណោះ ហើយចំពោះតម្លៃដីវិញគឺ ១៣$ ក្នុងមួយម៉ែត្រការ៉េ ខុសពីអ្វីដែលជនសង្ស័យធ្លាប់បានអះអាងពីមុនមក ហើយបានមកទារប្រាក់បន្ថែមពីជនរងគ្រោះទៀត ជនរងគ្រោះក៏សួរនាំថាដីដែលត្រូវទិញចំនួន ប្រហែលជាង ១០ហិកតា ក្រោយនេះតើមាន ឯកសារពាក់ព័ន្ធនឹងដីទេ? អាចហៅម្ចាស់ដើមនៃដីមកជួបគ្នាដើម្បីសួរនាំបានទេ? ជនសង្ស័យបានត្រឹមយកកិច្ចសន្យាទិញលក់ដីពីរច្បាប់មកជូនជនរងគ្រោះ ឃើញថាម្ចាស់ដីឈ្មោះ [redacted] វណ្ណថា តែមិនឃើញមានហត្ថលេខា ឬបោះត្រាបញ្ជាក់ដោយអាជ្ញាធរមូលដ្ឋានសោះ ។ ដោយសារតែមានការសង្ស័យ ជនរងគ្រោះក៏បានស្រាវជ្រាវរកម្ចាស់ដីជាង ១០ ហិកតា នោះ ដើម្បីចង់ដឹងថាមានដីពិតប្រាកដនៅតំបន់នោះ និងឈ្មោះម្ចាស់ដីដូចការអះអាងរបស់ជនសង្ស័យដែរឬទេ? ជាលទ្ធផលឃើញថាម្ចាស់ដីពិតប្រាកដពុំមែនឈ្មោះ [redacted] វណ្ណថា នោះទេគឺជាអ្នកផ្សេងទៅវិញ ។ ដើម្បីឱ្យកាន់តែច្បាស់ជនរងគ្រោះបានទាក់ទងសុំការបំភ្លឺរកការពិត ពីខាងមន្ត្រីសុរិយោដីខេត្តសៀមរាបឃើញថា ពុំមែនជាឈ្មោះ អ៊ឹម វណ្ណថា ជាម្ចាស់ដីជាង ១០ ហិកតា នៅចំណុចកើតហេតុនោះទេ ។

-បានឃើញ ដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំលេខ ១៦០៥ "ឆ" ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

មិនព្រមដោះលែងឱ្យនៅក្រៅឃុំជនត្រូវចោទឈ្មោះ [redacted] ស៊ីម៉េង ភេទប្រុស អាយុ ៤៤ ឆ្នាំ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបររកស៊ីទិញលក់ដី ទីកន្លែងកំណើតនៅសង្កាត់លេខ ៥

Scanned with CamScanner

ខណ្ឌចាក់អង្រែលើ រាជធានីភ្នំពេញ ទីលំនៅមុនពេលឃាត់ខ្លួន [redacted] ខេត្តកណ្ដាល ប្រពន្ធឈ្មោះ [redacted] "រ" មានកូន ០៣ នាក់ ឪពុកឈ្មោះ [redacted] "ស" ម្ដាយឈ្មោះ [redacted] "រ" ទោសពីមុនគ្មាន ជានីតិជន ដែលត្រូវចោទប្រកាន់ពីបទឆបោក និងរំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅចំណុចភូមិប្រិយ៍ ឃុំខ្នារសណ្ដាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប កាលពីអំឡុងឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧, មាត្រា ៣៧៨ និងមាត្រា ៣៩១, មាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។

-បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ០១២ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ របស់លោក [redacted] ណូរ៉ា មេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] ស៊ីម៉េង ដែលប្ដឹងមិនសុខចិត្តនឹងដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំលេខ ១៦០៥ "ឆ" ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

-បានឃើញ សាលដីកាសភាស៊ើបសួរលេខ ៥៥ "ក្រ.III.ស.អ" ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ ៖

១-ទទួលបណ្ដឹងឧទ្ធរណ៍លេខ ០១២ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] ណូរ៉ា មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ស៊ីម៉េង គឺត្រឹមត្រូវតាមទម្រង់ច្បាប់ និងគតិច្បាប់។

២-បដិសេធចោលដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំលេខ ១៦០៥ "ឆ" ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្ដាល ជាអសារបង់។

៣-ដោះលែងជនត្រូវចោទឈ្មោះ [redacted] ស៊ីម៉េង ភេទប្រុស អាយុ ៤៤ឆ្នាំ ជនជាតិខ្មែរ (អត្តសញ្ញាណដូចខាងលើ) ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ ឆបោក និងរំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅភូមិប្រិយ៍ ឃុំខ្នារសណ្ដាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប កាលពីអំឡុងឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧, ៣៧៨, ៣៩១ និងមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ ឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន។

៤-បង្គាប់ឱ្យលោកប្រធានពន្ធនាគារខេត្តកណ្ដាល ដោះលែងជនត្រូវចោទឈ្មោះ [redacted] ស៊ីម៉េង ភេទប្រុស អាយុ៤៤ឆ្នាំ ជនជាតិខ្មែរ ជាបន្ទាន់ករណីជនត្រូវចោទរូបនេះគ្មានជាប់ឃុំខ្លួនពីបទល្មើសព្រហ្មទណ្ឌផ្សេងទៀតទេ។

៥-ដាក់ជនត្រូវចោទឈ្មោះ [redacted] ស៊ីម៉េង ភេទប្រុស អាយុ ៤៤ឆ្នាំ ជនជាតិខ្មែរ ឱ្យស្ថិតនៅក្រោមកាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការដូចខាងក្រោម៖

ក.មិនត្រូវផ្លាស់ប្ដូរលំនៅឋានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។

ខ.ត្រូវឆ្លើយតបនឹងការកោះហៅពីគ្រប់បុគ្គលដែលចាត់តាំងដោយចៅក្រមស៊ើបសួរ។

គ.ត្រូវចូលបង្ហាញខ្លួននៅប៉ុស្តិ៍នគរបាលរដ្ឋបាល ឃុំទួលពេជ្រ ស្រុកអង្គស្នួល ខេត្តកណ្ដាល ០១ (មួយ) ខែម្ដង រៀងរាល់ថ្ងៃទី០១ នៃខែនីមួយៗចាប់ពីពេលនេះតទៅ។



Scanned with CamScanner

ករណីជនត្រូវចោទរូបនេះ គេចវេសដោយចេតនាពីកាតព្វកិច្ចត្រួតពិនិត្យផ្លូវតុលាការដូចខាងលើ ចៅក្រមស៊ើបសួរអាចសម្រេចឱ្យឃុំខ្លួនជនត្រូវចោទជាបណ្ដោះអាសន្នបាន យោងតាមមាត្រា ២២៣ និង មាត្រា ២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

សាលដីកានេះបានប្រកាសជាអសាធារណៈ នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩ បើកសិទ្ធិប្ដឹងសាទុក្ខ ក្នុងកំណត់ច្បាប់។

-បានឃើញ បណ្ដឹងសាទុក្ខលេខ១៨៦ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩ របស់លោក ចាន់ ម៉ាលីស៊ីន មេធាវីការពារសិទ្ធិឱ្យឈ្មោះ [redacted]ស៊ីបី ដែលប្ដឹងមិនសុខចិត្តនឹងសាលដីកាសភាស៊ើបសួរលេខ ៥៤ "ក្រ. III.ស.អ" ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

## នាពេលសវនាការ

-ចៅក្រមបានអានរបាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូល ធ្វើសេចក្ដីសន្និដ្ឋានសុំថា៖ សភាស៊ើបសួរសាលាឧទ្ធរណ៍ បានសម្រេចបដិសេធចោលដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំលេខ ១៦០៥ "ឆ" ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាលជាអសារបង់គឺ មិនត្រឹមត្រូវនោះទេ ។ ផ្អែកតាមអង្គហេតុ និងភស្តុតាងគឺ ជនជាប់ចោទបានទទួលប្រាក់ពីជនរងគ្រោះមានទំហំទឹកប្រាក់ជាច្រើន ដើម្បីយកទៅទិញដីរហូតដល់ទៅចំនួន ១៤ ហិចតា ស្មើរហ្នឹង ១៤០.០០០ ម៉ែត្រការ៉េ ក្រោយមកជន ជាប់ចោទថា បានទិញដីបានចំនួន ១០ ហិចតា តែលទ្ធផលដីទាំងនោះគឺ ពុំឃើញមានឈ្មោះ និងឯកសារ ណាមួយលេខពិតប្រាកដតាមទម្រង់បែបយថាភូតនោះឡើយ នេះជាអំពើភូតកុហក និងមានចេតនាឆបោក ពិតប្រាកដ។ ម្យ៉ាងទៀត ការសម្រេចរបស់សាលាឧទ្ធរណ៍ គឺផ្អែកលើជនត្រូវចោទមានអាស័យដ្ឋាន ច្បាស់លាស់មានមុខរបរពិតប្រាកដ ជនត្រូវចោទមានជំងឺប្រចាំកាយ ត្រូវការព្យាបាលជាប្រចាំ និងមាន សេរីភាពជានិច្ចដូចដែលមានចែងក្នុងមាត្រា ២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងគប្បីដាក់ឱ្យជនត្រូវចោទ ស្ថិតក្រោមកាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការតាមមាត្រា ២២៣ និងមាត្រា ២៣០ នៃក្រមនីតិវិធី ព្រហ្មទណ្ឌ។ ចំណុចនេះសាលាឧទ្ធរណ៍មិនបានពិចារណាទៅលើភស្តុតាង ដែលជនត្រូវចោទមានជម្ងឺតែពុំ មានឯកសារចេញពីមន្ទីរពេទ្យនៅឡើយ ហើយការអនុវត្តតាមមាត្រា ២២៣ គឺគ្រាន់តែជាវិធានការដើម្បីឱ្យ ជនត្រូវចោទគោរពកាតព្វកិច្ចតែប៉ុណ្ណោះ តែពុំបានអនុវត្តឱ្យបានពេញលេញតាមលក្ខខណ្ឌ ដែលតម្រូវឱ្យ ជនត្រូវចោទដាក់ធានាដូចដែលមានចែងនៅក្នុងចំណុចទី៩ ក្នុងថាខណ្ឌនៃច្បាប់នេះឡើយ ដើម្បីកុំឱ្យបាត់ ផលប្រយោជន៍ដើមបណ្ដឹងនោះ។ ដូចនេះ ការសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំជនត្រូវចោទរបស់ ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាលនោះ គឺត្រឹមត្រូវតាមមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ហើយ។



Scanned with CamScanner

តំណាងមហាអយ្យការស្នើក្រុមប្រឹក្សាជំនុំជម្រះសម្រេច៖

១.ទទួលបណ្តឹងសាទុក្ខលេខ ១៩៦ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩ របស់លោក [redacted] ម៉ាលីស៊ីន ជាអ្នកតំណាងដោយអាណត្តិឱ្យដើមបណ្តឹងរដ្ឋប្បវេណី [redacted] ស៊ីប៊ីវ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

២.បដិសេធសាលដីកាព្រហ្មទណ្ឌលេខ ៥៥ "ក្រ.III.ស.អ" ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ ទុកជាអសាបង់។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

**១-យល់ឃើញថា** បណ្តឹងសាទុក្ខលេខ ១៩៦ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩ របស់លោក [redacted] ម៉ាលីស៊ីន អ្នកតំណាងដោយអាណត្តិឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ីប៊ីវ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបានតាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ មាត្រា ៤១៧ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**២-យល់ឃើញថា** មហាអយ្យការអមតុលាការកំពូលបានធ្វើការជូនដំណឹងពីកាលបរិច្ឆេទ នៃសវនាការដល់ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ស្របតាមមាត្រា ៤៣៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌរួចហើយ ប៉ុន្តែជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណីអវត្តមាន។ តាមមាត្រា ៤៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តុលាការកំពូលមិនចាំបាច់ស្តាប់ចម្លើយជនត្រូវចោទទេ ចំពោះរឿងក្តីនេះ ដូច្នេះតុលាការកំពូលអាចបន្តសវនាការបាន។

**៣-យល់ឃើញថា** ការដែលសភាស៊ើបសួរសាលាឧទ្ធរណ៍ បានសម្រេចដោះលែងជនត្រូវចោទដោយសំអាងហេតុថា អង្គហេតុនៃការចោទប្រកាន់ចំពោះជនត្រូវចោទ ជាទំនាក់ទំនងគតិយុត្តនៃកាតព្វកិច្ចក្នុងកិច្ចសន្យារដ្ឋប្បវេណីដែលគូភាគីដើមបណ្តឹងរដ្ឋប្បវេណី និងជនត្រូវចោទបានព្រមព្រៀងគ្នាដាក់ភាគហ៊ុន៥០%ម្នាក់ ដើម្បីទិញលក់ដី និងធ្វើសំណង់លក់យកផលចំណេញចែកគ្នា ហើយបទចោទប្រកាន់លើជនត្រូវចោទស្ថិតក្នុងវិមតិសង្ស័យនៅឡើយ ត្រូវការស៊ើបអង្កេតឱ្យបានល្អិតល្អន់ជាមុនសិនមុនការឃុំខ្លួន ព្រោះអាចបណ្តាលឱ្យប៉ះពាល់ដល់សិទ្ធិ សេរីភាពបូរណភាពបុគ្គល។ ជនត្រូវចោទមានក្រុមគ្រួសារ ប្រពន្ធកូនតូចៗក្នុងបន្ទុកត្រូវការជួយជ្រោមជ្រែងជីវភាពគ្រួសារ, មានទីលំនៅ និងមុខរបរពិតប្រាកដ ជាពិសេស ជនត្រូវចោទមានជំងឺប្រចាំកាយត្រូវការព្យាបាលជាប្រចាំដែលគប្បីពិចារណា និងសម្រេចអនុញ្ញាតឱ្យជនត្រូវចោទនៅក្រៅឃុំ ដោយផ្អែកតាមគោលការណ៍ ជនត្រូវចោទត្រូវតែមានសេរីភាពជានិច្ច ដូចមានចែងក្នុងមាត្រា ២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌនោះ គឺមានលក្ខណៈសមស្របហើយ។ តុលាការកំពូលឯកភាពតាមសំអាងហេតុនេះ។



Scanned with CamScanner

៤-យល់ឃើញថា សាលដីកាលេខ ៥៤ “ក្រ.III.ស.អ” ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៩ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះត្រឹមត្រូវតាមគតិច្បាប់ហើយ។

## ហេតុដូច្នេះសម្រេច៖

១-បដិសេធបណ្តឹងសាទុក្ខលេខ ១៩៦ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩ របស់លោក [redacted] ម៉ាលីស៊ីន អ្នកតំណាងដោយអាណត្តិឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ុប៊ីរ ។

២-តម្កល់សាលដីកាលេខ ៥៤ “ក្រ.III.ស.អ” ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៩ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍។

៣-សាលដីកានេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០។

Scanned with CamScanner